**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងលើការព្យួរកិច្ចសន្យាការងារ

សៀមរាប ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣

ក្នុងនាមយើងខ្ញុំជានិយោជិតដែលបម្រើការក្នុង សណ្ឋាគារ ប៉ាស៊ីហ្វិក ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៦អា ភូមិកសិកម្ម សង្កាត់ស្រះង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ពិតជាបានព្រមព្រៀង និងឯកភាពជាមួយសហគ្រាសក្នុងការព្យួរកិច្ចសន្យាការងារបន្តរបស់និយោជិតសរុប ១៣១នាក់ ក្នុងនោះមានស្ត្រី ៧៨នាក់ រយៈពេលបន្ត ៥៧ថ្ងៃ គិតចាប់ពីថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ ដោយសារតែក្រុមហ៊ុន ប្រឈមមុខចំពោះការបាត់បង់ប្រាក់ចំនូល ដោយពុំសូវមានភ្ញៀវមកស្នាក់នៅដោយសារតែការរីករាលដាលយ៉ាងខ្លាំងក្លានៃការកើនឡើងជាសាកល នៃជំងឺកូវីដ១៩។

ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារបុគ្គលិក ក្រុមហ៊ុនមិនមានការឧបត្ថម្ភជូនអ្វីទាំងអស់ដល់បុគ្គលិក។

ដើម្បីជាសក្ខីភាពនៃការព្រមព្រៀង យើងខ្ញុំបានយល់ព្រមដោយស្ម័គ្រចិត្ត ក្នុងការផ្តិតមេដៃ ទុកជាភស្តុតាងនៅចំពោះមុខច្បាប់។

| តំណាងនិយោជិត | តំណាងនិយោជក |
|---|---|
| ស្នាមមេដៃស្តាំ | ស្នាមមេដៃស្តាំ |

ព្រះរាជាណាចក្រកម្ពុជា
សណ្ឋាគារ ប៉ាស៊ីហ្វិក
ខេត្តសៀមរាប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុនៈ សណ្ឋាគារប៉ាស៊ីហ្វិក**
លេខបញ្ជីពាណិជ្ជកម្មៈ ០០០១០២៣៣
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ១០០០៩៩៥
លេខគណនីធនាគារៈ
អាសយដ្ឋានៈ លេខផ្ទះ លេខផ្លូវ 6A ភូមិ កសិកម្ម ឃុំ/សង្កាត់ ស្រង៉ែ ក្រុង/ស្រុក/ខណ្ឌ ក្រុងសៀមរាប រាជធានី/ខេត្ត សៀមរាប
ទូរស័ព្ទលេខ៖ ០៦៣ ៧៦ ១៨ ១៨ អ៊ីមែល (E-mail)៖ siemreap@pacifichotel.com.kh

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប
**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ១៣១នាក់ រយៈពេល ៥៧ថ្ងៃ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំជំងឺរាលដាលកូវីដ១៩ (Covid-19) ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៣១នាក់ (ស្រី ៧៨នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២៤១នាក់ (ស្រី ១២៦នាក់) រយៈពេល ៥៧ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិត ចំនួន ០០ ដុល្លារអាមេរិក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

សៀមរាប ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

ព្រះរាជាណាចក្រកម្ពុជា
សណ្ឋាគារ ប៉ាស៊ីហ្វិក
ខេត្តសៀមរាប

ក្រុង. តុ. ៣

សូមភ្ជាប់មកជាមួយៈ
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និង ជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- អាជ្ញាប័ណ្ណទេសចរណ៍ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់ (វិស័យទេសចរណ៍)
- វិញ្ញាបនបត្រចុះបញ្ជីកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)